ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៤៩១
ចុះថ្ងៃទី ២២-០២-២០១១

**សាលក្រមព្រហ្មទណ្ឌ**
**លេខ : ៥១ (ង)**
**ចុះថ្ងៃទី ២២-០៦-២០១១**

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១ ដោយមានសមាសភាពជំនុំជម្រះ ដូចតទៅ :

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩១ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១១ ដែលមានជនជាប់-ចោទ :

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត នៅភូមិលេខ២ ឃុំតងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) នៅលីវ ទោសពីមុនគ្មាន ។ ឃាត់ខ្លួនថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ និងឃុំខ្លួន តាមដីកាសំរេចអោយឃុំខ្លួនបណ្តោះអាសន្នលេខ ៩១៩ ត.ព្រ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១១ និងដីកាបង្គាប់អោយឃុំខ្លួនលេខ ៣២៤-ត.ព្រ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

២-ឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ចាយ ទីកន្លែងកំណើតនៅភូមិសប្រច័ន្ទ ឃុំសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ប្តីឈ្មោះ [redacted] មានកូន ០៣នាក់ ។ គេចខ្លួន មានដីកាបង្គាប់អោយចាប់ខ្លួនលេខ ១៤៦ ត.ព្រ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅភូមិកំពង់បឹង ឃុំមាន ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម



Scanned by CamScanner

៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្តីឈ្មោះ [redacted] កូនគ្មាន ។ តេចខ្លួន មានដីកាបង្គាប់អោយចាប់ខ្លួនលេខ ១៤៧ ត.ព្រ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

***អង្គហេតុនៃរឿង មានដូចតទៅ :***

កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ វេលាម៉ោង ១៥:០០ នាទី កំលាំងសមត្ថកិច្ចនគរបាលរដ្ឋបាលទំ-នប់ទឹក បានសហការណ៍ជាមួយកំលាំងសាលាសង្កាត់ទំនប់ទឹកបានចុះធ្វើការល្បាតត្រួតពិនិត្យក្នុងភូមិសាស្ត្រដែនដីរបស់ខ្លួន ហើយបានត្រួតពិនិត្យផ្ទះ ដែលឈ្មោះ [redacted] ជួលស្នាក់នៅ ស្ថិតនៅផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ បានប្រទះឃើញឧបករណ៍សំរាប់ជក់គ្រឿងញៀនចំនួន ០២ (ពីរ) និងទុយោជ័រតូចៗមួយចំនួន ហើយសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] យកមកសាកសួរ ទើបដឹងថា ឈ្មោះ [redacted] ទិញគ្រឿងញៀនពីឈ្មោះ [redacted] ហៅ [redacted] ពីឈ្មោះ [redacted] ហៅ [redacted] ពីឈ្មោះ [redacted] យកមកលក់បន្តអោយឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ហើយបានផ្តល់នូវឧបករណ៍សំរាប់ជក់គ្រឿងញៀនអោយអ្នកទាំងនោះជក់នៅផ្ទះដែលឈ្មោះ [redacted] ជួលស្នាក់នៅទៅទៀតផង ។

-បានឃើញ របាយការណ៍សំយោគលេខ ០៤១/១១ របក ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១១ របស់អធិ-ការដ្ឋាននគរបាលខណ្ឌចំការមន ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦៦៥ អយក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១០៦២ ដជរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចរក្សាទុកជនត្រូវចោទអោយនៅក្នុងឃុំបណ្តោះអាសន្នលេខ ១០៦១ ដជរ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

***នាពេលសវនាការ :***

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា : ខ្លួនបានជួលផ្ទះតាស៊ីម ស្នាក់នៅ មួយថ្ងៃ ៥០០០ (ប្រាំពាន់) រៀល ដោយខ្លួនមានជីវភាពក្រីក្រ និងគ្មានមុខរបរ ក៏បែកគំនិតទិញគ្រឿងញៀនពីឈ្មោះ [redacted] ភេទស្រី. ឈ្មោះ [redacted] ភេទស្រី និងឈ្មោះ [redacted] ភេទប្រុស យកមកលក់បន្តអោយឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលជាអ្នកជក់គ្រឿងញៀន ហើយខ្លួនក៏បានអោយឧបករណ៍សំរាប់ជក់គ្រឿងញៀន



Scanned by CamScanner

ទៅអ្នកទាំងនោះជក់នៅផ្ទះរបស់ខ្លួន ពេលសមត្ថកិច្ចចុះមកធ្វើការត្រួតពិនិត្យប្រទះឃើញ ក៏បានឃាត់ខ្លួន និងអ្នកជក់គ្រឿងញៀនទាំងនោះតែម្តង ។

-តាមអំណាចចំលើយឈ្មោះ[redacted]ថា : នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួនបានមកផ្ទះឈ្មោះ[redacted]ហើយបានអោយប្រាក់ទៅឈ្មោះ[redacted]ចំនួន ២០០០០(ពីរម៉ឺន)រៀល យកទៅទិញថ្នាំញៀន ប្រភេទពណ៌សម៉ដ្ឋ មួយកូនកញ្ចប់តូច មកជក់ ពេលជក់ហើយ ក៏ដេកនៅផ្ទះឈ្មោះ[redacted]ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-តាមអំណាចចំលើយឈ្មោះ[redacted] ថា : កាលពីថ្ងៃសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួន និងឈ្មោះ[redacted]ហៅ[redacted]បានចូលប្រាក់គ្នាម្នាក់ ១០០០០(មួយម៉ឺន)រៀល ជិះម៉ូតូឌុបចេញពីផ្សារដើមគរ មកភូមិផ្ទេរ ដើម្បីជក់គ្រឿងញៀន ពេលមកដល់មានមនុស្សប្រុសម្នាក់ហៅពួកខ្លួនអោយចូលទៅក្នុងផ្ទះរបស់វាជក់ថ្នាំញៀន ពេលពួកខ្លួនហុចប្រាក់អោយវា២០០០០(ពីរម៉ឺន)រៀល វាក៏អោយគ្រឿងញៀនមកពួកខ្លួន ០១(មួយ)កូនកញ្ចប់ រួចយកឧបករណ៍សំរាប់ជក់គ្រឿងញៀនមករៀបចំអោយពួកខ្លួនទាំងពីរនាក់ជក់ ពេលពួកខ្លួនជក់ហើយ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

-តាមអំណាចចំលើយឈ្មោះ[redacted]ថា : កាលពីថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួននោះ ខ្លួន និងឈ្មោះ[redacted]ហៅ[redacted]បានចូលប្រាក់គ្នាម្នាក់ ១០០០០(មួយម៉ឺន)រៀល ជិះម៉ូតូឌុបចេញពីផ្សារដើមគរមកភូមិផ្ទេរ ដើម្បីជក់គ្រឿងញៀន ពេលមកដល់មានមនុស្សប្រុសម្នាក់ហៅពួកខ្លួនអោយចូលទៅក្នុងផ្ទះរបស់វា ពេលពួកខ្លួនហុចប្រាក់អោយវាចំនួន ២០០០០(ពីរម៉ឺន)រៀល វាក៏អោយថ្នាំញៀនមកពួកខ្លួនមួយកញ្ចប់តូច រួចយកឧបករណ៍សំរាប់ជក់គ្រឿងញៀនមករៀបចំអោយពួកខ្លួនជក់ ពេលជក់រួចសមត្ថកិច្ចចូលមកឃាត់ខ្លួនតែម្តង ។

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា : រឿងនេះ ជន-ជាប់ចោទឈ្មោះ[redacted]បានឆ្លើយសារភាពថា ខ្លួនបានទៅទិញគ្រឿងញៀនពីឈ្មោះ[redacted]ហៅ[redacted]ឈ្មោះ[redacted]ហៅ[redacted]និងពីឈ្មោះ[redacted]យកមកលក់អោយអ្នកជក់បន្តទៀត ព្រមទាំងផ្តល់ទីកន្លែង និងឧបករណ៍សំរាប់ជក់គ្រឿងញៀនថែមទៀត ហើយការឆ្លើយសារភាពនេះ ក៏មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងដែលមានក្នុងសំណុំរឿងផងដែរ ។ ក្នុងនាមខ្ញុំជាតំណាងអយ្យការ ខ្ញុំសូមអោយតុលាការសម្រេចកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ[redacted]ហៅ[redacted]និងឈ្មោះ[redacted]ហៅ[redacted] ពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ទៅជាបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមា-ត្រា ៣៣ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងប្តឹងសុំអោយតុលា-ការបញ្ជូលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩១ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើឈ្មោះ[redacted]បទ : សម្រួលដោយចេតនាអោយជនណាម្នាក់ប្រើប្រាស់ ដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តិនៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាល



Scanned by CamScanner

ពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៥.២ថ្មី កថាខណ្ឌ ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមបញ្ញត្តិមាត្រា ៣៤៨ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរដល់តុលាការជាសំដីចុងក្រោយបង្អស់ថា : សូមតុលា-ការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

## សំអាងហេតុ

***ក្រោយពីបាន :***

ស្តាប់ចំលើយជនជាប់ចោទឈ្មោះ [redacted]

ស្តាប់អំណានចំលើយសាក្សីបំភ្លឺ

ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទឈ្មោះ [redacted]

ពិនិត្យ ភស្តុតាង ឯកសារនានា

***ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ឃើញថា :***

១-កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ នៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ពិតជាមានករណីជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តឡើងដោយជន-ជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ហៅ [redacted] ប្រាកដមែន ។

២-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញគ្រឿងញៀនពីឈ្មោះ [redacted] ភេទស្រី ពីឈ្មោះ [redacted] ភេទស្រី និងពីឈ្មោះ [redacted] ភេទប្រុស យកមកលក់បន្តអោយឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលជាអ្នកជក់គ្រឿងញៀន ដើម្បីបានប្រាក់ចំណេញ ហើយខ្លួនបានអោយឧបករណ៍សំរាប់ជក់គ្រឿងញៀនជក់នៅផ្ទះរបស់ខ្លួនដែលជួលស្នាក់នៅ ។ ចំលើយនេះ មានភាពស៊ីសង្វាក់ទៅនឹងចំលើយឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ងភស្តុតាងនានា ដែលមានក្នុងសំណុំ-រឿងផងដែរ ។

៣-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ ត្រូវបានបញ្ជូនមកជំនុំជម្រះ ពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែផ្អែកតាមអង្គហេតុនៃរឿងនិងភស្តុតាងនានា ដែលមានក្នុងសំណុំរឿង ឃើញថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទទាំងបីនាក់មិនមែនជាអំពើចែកចាយគ្រឿងញៀនខុច្បាប់ទេ គឺជាអំពើជួញដូរគ្រឿងញៀនខុសច្បាប់ ដែលគប្បីតុលាការសម្រេចកែប្រែបទ



Scanned by CamScanner

បញ្ញត្តិដែលចោទប្រកាន់លើជនជាប់ចោទទាំងបីនាក់ ពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ទៅជាបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញ ។

៤-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំអោយតុលាការកែប្រែបទបញ្ញត្តិដែលចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ហៅ [redacted] ពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ទៅជាបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ តាមបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥-មានពិរុទ្ធភាពលើឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ. ឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ ពីបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តិទៅ ចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ហៅ [redacted] ធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងជាអំពើដែលធ្វើអោយសង្គមជាតិកើនឡើង នូវបទល្មើសដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងញៀន និងធ្វើអោយប្រជាពលរដ្ឋមានការព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ដែលបណ្តាលមកពីអ្នកប្រើប្រាស់គ្រឿងញៀន ធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបំពានទៅលើនីត្យានុកូលភាពសង្គមដែលច្បាប់បានការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

៧-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួន ដោយស្មោះត្រង់គ្មានលាក់លៀម ។ ស្ថានទាំងនេះអាចអោយតុលាការពិចារណាសម្រេចពីស្ថានសំរាលទោសអោយបាន ។

៨-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា ខ្លួនបានលក់គ្រឿងញៀនអោយទៅឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលជាអ្នកជក់គ្រឿងញៀន ហើយខ្លួនក៏បានអោយឧបករណ៍សំរាប់ជក់គ្រឿងញៀនទៅអ្នកទាំងនោះជក់នៅផ្ទះរបស់ខ្លួន ។ ចម្លើយនេះ មានភាពស៊ីសង្វាក់ទៅនិងចម្លើយឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] និងភស្តុតាងនានាដែលមានក្នុងសំណុំរឿងផងដែរ ដែលសកម្មភាពរបស់ឈ្មោះ [redacted] នេះ ជាអំពើល្មើសព្រហ្មទណ្ឌ សម្រួលដោយចេតនាអោយជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

៩-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំអោយតុលាការបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩១ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទៅព្រះរាជអាជ្ញាអមសា–



Scanned by CamScanner

លាងបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើឈ្មោះ [redacted] ពីបទ : សម្រួលដោយចេតនាអោយជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប្រព្រឹត្តិនៅ ចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៥.២ថ្មី កថាខណ្ឌ ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមបញ្ញត្តិមាត្រា ៣៤៨ កថាខណ្ឌ ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ការប្តឹងសុំនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## ហេតុដូច្នេះសំរេច

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ. ឈ្មោះ [redacted] ហៅ [redacted] ភេទ ស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ហៅ ហ្សា ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ ពីបទ : ចែកចាយគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុច ផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ទៅជាបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុច ផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ ។

២-ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.000.000(បួនលាន)រៀល ដាក់ចូលជាថវិការដ្ឋ ពីបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ផ្តន្ទាទោសឈ្មោះ [redacted] ហៅ [redacted] ភេទ ស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៣(បី) ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន និងពិន័យជាប្រាក់ ចំនួន ៤.000.000(បួនលាន)រៀល ដាក់ចូលជាថវិការដ្ឋ ពីបទ : ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ចេញដីកាបង្គាប់អោយចាប់ខ្លួនឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់បាយ ទីកន្លែងកំណើតនៅ ភូមិសប្រច័ន្ទ ឃុំសប្រច័ន្ទ ស្រុកពារាំង ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស្លាប់ )



Scanned by CamScanner

ម្តាយឈ្មោ[redacted]រស់) ប្តីឈ្មោះ[redacted]ានកូន ០៣(បី)នាក់ និងឈ្មោះ [redacted]ហៅ [redacted]ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែង កំណើតនៅភូមិកំពង់បឹង ឃុំមាន ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]រស់) ម្តាយឈ្មោ[redacted](រស់) ប្តីឈ្មោះ[redacted]នគ្មាន យកមកទទួលទោស តាមអំណាចនៃសាលក្រមព្រហ្មទណ្ឌនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥-បញ្ជូលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩១ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១១ របស់សាលាដំបូងរាជ-ធានីភ្នំពេញ ជូនទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើឈ្មោ[redacted]ភេទប្រុស អាយុ ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត នៅ ភូមិលេខ២ ឃុំតងជ័យ ស្រុកអូររាំងឪ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅផ្ទះជួល ផ្លូវលេខ ៤៣៤ ក្រុម៣៤ ភូមិ ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំ-ការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](រស់) ម្តាយឈ្មោ[redacted](រស់) នៅលីវ ទោសពីមុនគ្មាន ពិបទ : **សម្រួលដោយចេតនាអោយជនណាម្នាក់ប្រើប្រាស់ដោយខុសច្បាប់នូវគ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ** ប្រព្រឹត្តិនៅ ចំណុចផ្ទះ ជួល ផ្លូវលេខ ៤៣៤ ក្រុម ៣៤ ភូមិ៤ សង្កាត់ទំនប់ទឹក ខណ្ឌចំ-ការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១១ តាមបញ្ញត្តិមាត្រា ៣៥.២ថ្មី កថាខណ្ឌ ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ផ្អែកតាមមាត្រា ៣៤៨ កថាខណ្ឌ ៣ នៃក្រមនីតិ-វិធីព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១ និងប្រកាសជាសាធារណៈ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១១ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]បាំងមុខជនជាប់ចោទឈ្មោះ[redacted]ហៅ[redacted]ឈ្មោះ[redacted]ហៅ[redacted] ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| --- | --- |
| ហត្ថលេខា និងត្រា[redacted] | ហត្ថលេខា និងត្រា : [redacted] |

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១១

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner